ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៩១៣...០១៣...០២៨...ប្រកាសព័ត៌មាន

*ថ្ងៃចន្ទ ១៤កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧*
*ខេត្តព្រះសីហនុ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៣ របស់ធនាគារជាតិនៃកម្ពុជា

នៅថ្ងៃអាទិត្យ ១៣កើត ដល់ថ្ងៃចន្ទ ១៤កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៣០-៣១ ខែកក្កដា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា នៅសណ្ឋាគារឆ្នេរសុខា ខេត្តព្រះសីហនុ។ សន្និបាតនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងអបអរសាទរនិងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០២៣ និងទិសដៅការងារចម្បងៗសម្រាប់ឆមាសទី២ សំដៅឈានទៅបន្តសម្រេចឱ្យបានជោគជ័យថ្មីៗបន្ថែមទៀតសម្រាប់ប្រព័ន្ធធនាគារក៏ដូចជាសេដ្ឋកិច្ចកម្ពុជាទាំងមូល។

នៅឆមាសទី១ ឆ្នាំ២០២៣នេះ អតិផរណារួមជាមធ្យមមានកម្រិត ១,២% ទាបជាងឆមាសទី២ ឆ្នាំ២០២២ (៤,១%) និងឆមាសទី១ ឆ្នាំ២០២២ (៦,៦%)។ ក្នុងស្ថានភាពដែលតម្លៃប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារអន្តរជាតិមាននិន្នាការកើនឡើង ប្រាក់រៀលមានស្ថិរភាពល្អក្នុងកម្រិតជាមធ្យម ៤.០៩៨រៀលក្នុង១ដុល្លារអាមេរិក។ ទុនបម្រុងអន្តរជាតិគិតត្រឹមឆមាសទី១នេះ មានចំនួន ១៨,៤ ប៊ីលានដុល្លារអាមេរិក កើនឡើង ៣,២% ធៀបនឹងចុងឆ្នាំ២០២២ ដែលអាចធានាការនាំចូលទំនិញនិងសេវាបាន៧ខែ ខ្ពស់ជាងកម្រិតអប្បបរមា ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។ ប្រព័ន្ធធនាគារកម្ពុជាសម្រេចបានលទ្ធផលល្អ និងបានរួមចំណែកយ៉ាងសំខាន់ដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងគាំទ្រកំណើនសេដ្ឋកិច្ចនៅឆ្នាំ២០២៣ ដែលត្រូវបានរំពឹងថានឹងសម្រេចបានក្នុងរង្វង់ ៥,៥% ដែលគាំទ្រដោយកំណើនខ្ពស់នៃវិស័យទេសចរណ៍ និងភាពប្រសើរឡើងនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ទោះបីជាវិស័យកសិកម្ម និងសំណង់បន្តទទួលបានកំណើនទាប។

ប្រព័ន្ធធនាគារកម្ពុជាត្រូវបានបន្តអភិវឌ្ឍឱ្យកាន់តែរឹងមាំ ដែលឆ្លុះបញ្ចាំងតាមរយៈទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារដែលមានកំណើន ៩,៩% ដល់ ៣៣៣,៤ ទ្រីលានរៀល (៨២,២ ប៊ីលានដុល្លារអាមេរិក)។ ឥណទានមានកំណើន ១៣,៤% ដល់ ២៣៧,៥ ទ្រីលានរៀល (៥៨,៦ ប៊ីលានដុល្លារអាមេរិក) ខណៈប្រាក់បញ្ញើអតិថិជនមានកំណើន ៦,៤% ដល់ ១៧៩,៨ ទ្រីលានរៀល (៤៤,៤ ប៊ីលានដុល្លារ


ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

អាមេរិក)។ អនុបាតឥណទានមិនដំណើរការបន្តស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន បើទោះបីជាបានកើនឡើងបន្តិចបន្ទាប់ពីការបញ្ចប់វិធានការឥណទានរៀបចំឡើងវិញកាលពីចុងខែមិថុនា ឆ្នាំ២០២២។

ប្រព័ន្ធទូទាត់កម្ពុជាត្រូវបានបន្តអភិវឌ្ឍឱ្យកាន់តែទំនើប ដោយបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗជាបន្តបន្ទាប់ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាពនិងសុវត្ថិភាពខ្ពស់ ដើម្បីសម្រួលដល់ការដោះដូរទំនិញនិងសេវានៅក្នុងសេដ្ឋកិច្ចឱ្យកាន់តែមានភាពងាយស្រួលនិងឆាប់រហ័ស លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងគាំទ្រដល់ការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ទៅក្នុងតំបន់។ ក្នុងចំណោមប្រព័ន្ធទូទាត់ទាំងអស់ ប្រព័ន្ធទូទាត់បាគងបានបន្តលើកមុខមាត់ប្រព័ន្ធទូទាត់កម្ពុជានៅលើឆាកអន្តរជាតិ ដោយមានធនាគារកណ្តាលមួយចំនួន បានស្នើសុំរៀនសូត្រពីបទពិសោធន៍របស់ធនាគារជាតិនៃកម្ពុជា។

នៅឆ្នាំ២០២៣នេះ ទន្ទឹមនឹងការរំពឹងទុកប្រកបដោយសុទិដ្ឋិនិយម សេដ្ឋកិច្ចកម្ពុជាក៏ត្រូវប្រឈមនឹងហានិភ័យចម្បងៗរួមមាន៖ i/-កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចពិភពលោកនិងតំបន់ ii/-ភាពមិនច្បាស់លាស់នៃលំហូរមូលធន និងការរឹតត្បិតស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ iii/-ការប្រែប្រួលអាកាសធាតុដែលអាចបន្ថយកំណើនក្នុងវិស័យកសិកម្ម និង iv/-ឧក្រិដ្ឋកម្មសាយប័រដែលអាចធ្វើឱ្យរអាក់រអួលដល់ដំណើរការប្រព័ន្ធទូទាត់និងសេដ្ឋកិច្ចទាំងមូល។

ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជានឹងបន្តរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន ការពង្រឹងភាពធន់នៃប្រព័ន្ធធនាគារ ការលើកកម្ពស់ប្រសិទ្ធភាពនិងសុវត្ថិភាពប្រព័ន្ធទូទាត់ ព្រមទាំងត្រៀមខ្លួនដាក់ចេញនូវនយោបាយនិងវិធានការគាំទ្រចាំបាច់នានាប្រកបដោយភាពប្រុងប្រយ័ត្ននិងបត់បែនខ្ពស់ ស្របតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចជាក់ស្តែង។ ///

**ទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
អ៊ីមែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia ,
www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia ,
www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA